ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

កំពង់ផែស្វយ័តភ្នំពេញ
Phnom Penh Autonomous Port
លេខ:..០២៥០... ក.ស.ភ/PPAP

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ(ក.ស.ភ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនមេត្តាជ្រាបថា÷ យោងតាមលិខិតជូនដំណឹងលេខ១៨៩ សជណ.គប ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦របស់ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលបានសម្រេចយល់ព្រមពន្យារអាណត្តិរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៥ របស់កំពង់ផែស្វយ័តភ្នំពេញ រហូតដល់ពេលដែលសមាជិកជាអភិបាលចំនួនពីររូប រួមមានអភិបាលឯករាជ្យចំនួនមួយរូប និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនចំនួនមួយរូប ត្រូវបានជ្រើសរើស។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីចាត់ការកណ្តាល: អគារលេខ ៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១៨៩ សសរ.តប

មកដល់លេខ ១៦៧ ក.ស.ត
ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦
ម៉ោង ១៥:៥

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ**:ការស្នើសុំពន្យារអាណត្តិទី៥ របស់ក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញរហូតដល់ពេល សមាជិកជាអភិបាលឯករាជ្យចំនួនពីររូបត្រូវបានជ្រើសរើស។

**យោង** :-លិខិតលេខ៣៨២ សក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។
-ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចយល់ព្រមពន្យារអាណត្តិទី៥ របស់ក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញរហូតដល់ពេលសមាជិកជាអភិបាលឯករាជ្យចំនួនពីររូបត្រូវបានជ្រើសរើស។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**បណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី**

ចម្លងជូន :
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
--សាលារាជធានីភ្នំពេញ
-កំពង់ផែស្វយ័តភ្នំពេញ
-ឯកសារ កាលប្បវត្តិ